**សលាកប័ត្រព័ត៌មាន ៖** ការបង្ក្រាបទៅលើអ្នកប្រើប្រាស់ហ្វេសប៊ុកមានការកើនឡើង
**កាលប្បវត្តិ ៖** ខែសីហា ឆ្នាំ២០១៥ ដល់ខែកុម្ភៈ ឆ្នាំ២០១៦
**ទិដ្ឋភាពរួម ៖** ការកើនឡើងនូវចំនួននៃប្រជាពលរដ្ឋដែលត្រូវបានចាប់ខ្លួននាពេលថ្មីៗនេះដោយសារការបញ្ចេញមតិយោបល់នៅលើបណ្តាញអ៊ិនធឺណិត ព្រមទាំងការគំរាមកំហែងពីសំណាក់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ដែលទាំងនេះបានគំរាមដល់សេរីភាពខាងការបញ្ចេញមតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា "កម្ពុជា"។

## សេចក្តីផ្តើម

នៅប៉ុន្មានខែចុងក្រោយនេះ អ្នកប្រើប្រាស់អ៊ីនធឺណិតជាច្រើននាក់នៅក្នុងប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងការឃុំខ្លួន និងរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌដោយសារការបញ្ចេញមតិយោបល់នៅលើបណ្តាញអ៊ីនធឺណិត។ សលាកប័ត្រព័ត៌មាននេះលើកឡើងនូវករណីដែលបុគ្គលមួយចំនួនត្រូវបានចាប់ខ្លួន ឬទទួលរងការគំរាមកំហែង ព្រមទាំងគូសបញ្ជាក់ពីសារៈសំខាន់ពិតប្រាកដនៃសេរីភាពខាងការបញ្ចេញមតិក្នុងការរិះគន់ទៅលើមន្ត្រីសាធារណៈ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគំរាមចាត់វិធានការផ្លូវច្បាប់ម្តងហើយម្តងទៀតទៅលើអ្នករិះគន់រដ្ឋាភិបាល ដោយបង្កើតបាននូវបរិយាកាសដ៏អាប់អួដែលរារាំងដល់បុគ្គលនានាក្នុងការសម្តែងគំនិតយោបល់របស់ខ្លួនដោយសេរី ។ ការបង្កើតវប្បធម៌ដាក់ពិរុទ្ធខ្លួនឯងកំពុងកើតឡើងគួរឱ្យព្រួយបារម្ភខ្លាំងនៅក្នុងបរិបទនយោបាយបច្ចុប្បន្ន ខណៈដែលការបញ្ចេញទស្សនៈខុសៗគ្នាគឺមានសារៈសំខាន់ដើម្បីជានាដល់ដំណើរការល្អនៃលទ្ធិប្រជាធិបតេយ្យ។

សលាកប័ត្រព័ត៌មាននេះតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅប្រទេសកម្ពុជា។ មតិយោបល់ដែលបានលើកឡើងដោយអ្នកប្រើអ៊ីនធឺណិតដែលបានពិភាក្សានៅក្នុងករណីសិក្សាទាំងនេះពុំបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ ម.ស.ម.ក ឡើយ។

## ហ្វេសប៊ុក ៖ សមរភូមិថ្មីសម្រាប់សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា

យ៉ាងហោចណាស់មានមនុស្សប្រាំពីរនាក់ត្រូវបានចាប់ខ្លួន ដោយសារបង្ហោះសារឬបញ្ចេញមតិយោបល់តាមបណ្តាញអ៊ីនធឺណិតចាប់តាំងពីខែសីហា ឆ្នាំ២០១៥ កន្លងមក ហើយក្នុងចំណោមអ្នកទាំងនោះមានម្នាក់បន្តស្ថិតក្នុងពន្ធនាគារនៅឡើយ។ យ៉ាងហោចណាស់មនុស្សចំនួន ២៤ នាក់ រងការគំរាមកំហែងជាសាធារណៈចាប់តាំងពីខែសីហា ឆ្នាំ២០១៥ មក ដោយសារការបញ្ចេញមតិយោបល់នៅលើបណ្តាញសង្គម។ បើទោះបីជា ករណីទាំងអស់ខាងក្រោមនេះមិនមែនសុទ្ធតែជាការរិះគន់ដោយសុភវិនិច្ឆ័យ ឬ ក្នុងន័យស្ថាបនាក៏

ដោយ ក៏នេះបង្ហាញពីបរិយាកាសដ៏គួរឱ្យបារម្ភ ខណៈដែលបុគ្គលរិះគន់ទៅលើអ្នកនយោបាយល្បីៗតែងតែរង ការចាប់ខ្លួន ដោយសារតែការយល់ឃើញរបស់ពួកគេនៅលើបណ្ដាញសង្គម។

ករណីដែលល្បីនិងគួរឱ្យបារម្ភជាងគេនោះគឺពាក់ព័ន្ធនឹងការបង្ហោះសារនៅលើគេហទំព័រហ្វេសប៊ុក របស់និស្សិតវ័យ ២៥ ឆ្នាំ ម្នាក់ ឈ្មោះ គង់ រ៉ៃយ៉ា[1]។ បន្ទាប់ពីសរសេរសារបង្ហោះលើទំព័រហ្វេសប៊ុកកាលពីថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៥ អំពាវនាវឱ្យប្រជាពលរដ្ឋកម្ពុជាចូលរួម "*បដិវត្តន៍ពណ៌*" ។ លោកត្រូវបានចាប់ខ្លួន កាលពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៥ ក្រោយពេលមានព័ត៌មានមិនច្បាស់លាស់រយៈពេលពីសប្ដាហ៍មក ហើយគាត់ត្រូវបានចោទប្រកាន់នៅថ្ងៃបន្ទាប់ ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ បើទោះបីជាមានសវនាជា ច្រើនលើកនៅសាលាដំបូងរាជធានីភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ២០១៥ក៏ដោយ រហូតមកទល់ពេលនេះពុំទាន់មាន ការប្រកាសសាលក្រមស្ដាពរនៅឡើយទេ ហើយលោក គង់ រ៉ៃយ៉ា នៅតែស្ថិតក្រោមការឃុំខ្លួនបន្តទៀត។ ការ បង្ក្រាបម្ដងហើយម្ដងទៀតទៅលើមតិយោបល់ដ៏តូចមួយដែលអំពាវនាវឱ្យមានចលនាដោយសន្តិវិធីដើម្បីផ្លាស់ ប្ដូររបបនយោបាយនាំឱ្យមានប្រតិកម្មតបតវិញយ៉ាងធ្ងន់ធ្ងរដូច្នេះ។

ចំនួនករណីដែលអ្នកប្រើប្រាស់បណ្ដាញសង្គមត្រូវបានអាជ្ញាធរកំណត់មុខសញ្ញា បានកើនឡើងកាន់ តែច្រើននៅរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ នារីម្នាក់ត្រូវបានឃាត់ខ្លួន និងសួរចម្លើយអស់រយៈពេលមួយថ្ងៃពាក់ព័ន្ធនឹងការបង្ហោះសារនៅលើបណ្ដាញសង្គមហ្វេសប៊ុក ដែលលើក ឡើងថាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលមរណៈភាពបន្ទាប់ពីត្រូវបណ្ដាសា។ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ លោក ហ៊ុន ម៉ាណែត កូនប្រុសរបស់នាយករដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានប្រឆាំងអំពើភេរវកម្ម នៃក្រសួងការពារជាតិ បានដាក់ពាក្យបណ្ដឹងទៅកាន់អគ្គស្នងការនគរបាលជាតិចោទប្រកាន់ឈ្មោះ ឆាំ ចាន់នី ពីបទបរិហារកេរ្តិ៍ទៅលើរូបលោកនិងម្ដាយលោកគឺលោកជំទាវ ប៊ុន រ៉ានី នៅលើទំព័រហ្វេសប៊ុក ថាមានជាប់ពាក់ ព័ន្ធនឹងបទល្មើសព្រៃឈើ។[2] កាលពីថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៦ ពលរដ្ឋកម្ពុជាបីនាក់នៅកូរ៉េខាងត្បូងត្រូវបាន មន្ត្រីទូតកម្ពុជាសាកសួរពាក់ព័ន្ធនឹងវីដេអូឃ្លីបមួយតាំងពីឆ្នាំ២០១៤ ដែលបង្ហាញពីសកម្មភាពពួកគេដុតរូបថត និងជេរប្រមាថលើនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ដប់ថ្ងៃក្រោយមក មានវីដេអូឃ្លីបមួយទៀតមានទាំងរូបឯកអគ្គ រាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េខាងត្បូងគឺលោក ស៊ុត ឌីណា ដែលអ្នកទាំងបីរូបបានធ្វើការសុំទោសជា សាធារណចំពោះទង្វើរបស់ខ្លួននិងស្នើសុំការអត់ឱនទោស[3]។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦ លោក សុខ ទូច ប្រធានក្រុមស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជាទទួលបន្ទុកពិនិត្យផែនទីព្រំដែនកម្ពុជា វៀតណាម បាន

---

[1] អ៊ួច សូនី "និស្សិតម្នាក់ត្រូវបានសាកសួរពាក់ព័ន្ធនឹងការបញ្ចេញមតិយោបល់លើគេហទំព័រហ្វេសប៊ុក" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥)។ ព័ត៌មានពិស្ដារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1S7R9sT

[2] គ្លូបិលវីតណេស "គ្រួសារឈើរបស់កម្ពុជា៖ ការកាប់ឈើខុសច្បាប់ និងការយកទ្រព្យសម្បត្តិសាធារណៈ" (ខែមិថុនា ឆ្នាំ២០០៧) http://bit.ly/1W0wlSt [2] របាយការណ៍របស់អង្គការគ្លូបិលវីតណេស នៅឆ្នាំ២០០៧ បានភ្ជាប់ទំនាក់ទំនងគ្រួសាររបស់លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅនឹងការជួញដូរឈើខុសច្បាប់ ដោយអះអាងថាគ្រួសារនេះបានផ្ដល់និទណ្ឌភាពដល់ឧកញ៉ាមួយចំនួន ឱ្យរួចផុតពីទោសទណ្ឌពាក់ព័ន្ធនឹងសកម្មភាពកាប់ឈើខុសច្បាប់របស់គេ។ គ្រួសារលោកនាយករដ្ឋមន្ត្រីបានបដិសេធចំពោះការចោទប្រកាន់ទាំងនេះ។

[3] សែន ដាវិត "ពលករដែលប្រមាថលោក ហ៊ុន សែន ចេញសារភាព" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦)។ ព័ត៌មានពិស្ដារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1S6JmvF

គំរាមប្តឹងអតីតនិស្សិតសាកលវិទ្យាល័យខេមរៈម្នាក់ពីបទបរិហាកេរ្តិ៍ដែលបានបង្ហោះសារេិះគន់ថា សាកលវិទ្យាល័យបានទាមទារឱ្យមានការបង់ថ្លៃផ្សេងៗជាច្រើន ។[4] លោក សុខ ទូច ក៏ជាសាកលវិទ្យាធិការនិងជាម្ចាស់នៃសាកលវិទ្យាល័យខេមរៈផងដែរ។ ការគំរាមចាត់វិធានការផ្លូវច្បាប់ដោយស្ថាប័នឯកជននេះបានរឹតត្បិតសេរីភាពខាងការបញ្ចេញមតិរបស់និស្សិត ហើយការគំរាមនេះបានស្ងប់ស្ងាត់ទៅវិញបន្ទាប់ពីនិស្សិតស្រីរូបនោះបានធ្វើការសុំទោសជាសាធារណៈនិងលុបចោលសារមតិយោបល់នៅលើទំព័រហ្វេសប៊ុក។ ការប្រើបទល្មើសព្រហ្មទណ្ឌទៅលើការបរិហារកេរ្តិ៍ដើម្បីគាបសង្កត់លើមតិរិះគន់សាធារណៈកំពុងតែជាបញ្ហាធ្ងន់ធ្ងរដូចដែលលោក សុខ ទូច អះអាងថា "ធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះសាកលវិទ្យាល័យ" ជាដើម។

កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ អ្នកប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុកបានកែនិងចំអកទៅលើរូបថតរបស់លោកជំទាវ ប៊ុន រ៉ានី ភរិយារបស់នាយករដ្ឋមន្ត្រី នៅក្នុងដំណើរកំសាន្តលក្ខណៈគ្រួសារនាពេលកន្លងទៅថ្មីៗនេះ ដែលនាំឱ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្កោលទោសយ៉ាងធ្ងន់ធ្ងរដល់អ្នកទាំងនោះថា *"បំផ្លាញដល់កិត្តិយសក្រុមគ្រួសាររបស់លោក"* [5] ។ ពុំមានជនណាម្នាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងករណីនេះនៅឡើយទេ ប៉ុន្តែក្រសួងមហាផ្ទៃកំពុងស៊ើបអង្កេតករណីនេះជាមួយនឹងនគរបាលអន្តរជាតិក្នុងការស្វែងរកជនសង្ស័យដែលកំពុងរស់នៅក្រៅប្រទេស។ នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៥ នគរបាលបានចាប់ខ្លួនមនុស្សពីរនាក់ពាក់ព័ន្ធនឹងការបង្ហោះសំបុត្របញ្ជាក់កំណើតនៅលើទំព័រហ្វេសប៊ុកដែលថាខេត្តស្វាយរៀងស្ថិតក្នុងប្រទេសវៀតណាម [6] ។ សមាជិកក្រុមប្រឹក្សាឃុំរបស់គណបក្សសង្គ្រោះជាតិ ("គ.ស.ជ") លោក នង សារិទ្ធ ត្រូវបានចោទប្រកាន់ពីបទក្លែងឯកសារសាធារណៈ ហើយសកម្មជន គ.ស.ជ នៅមូលដ្ឋានមួយរូបផ្សេងទៀតគឺលោក សុខ សំអ៊ាន ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋបន្ទាប់ពីលោកបានបង្ហោះរូបភាពសំបុត្របញ្ជាក់កំណើតនៅលើទំព័រហ្វេសប៊ុក។ ករណីដាច់ដោយឡែកមួយទៀត នគរបាលបានបើកការស៊ើបអង្កេតកាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ដើម្បីកំណត់អត្តសញ្ញាណជនដែលបង្ហោះសំបុត្របញ្ជាក់កំណើតនៅលើបណ្តាញសង្គមហ្វេសប៊ុក ដែលថាខេត្តតាកែវស្ថិតក្នុងប្រទេសវៀតណាម។ អាជ្ញាធរបានគំរាមចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងជនណាដែលបង្ហោះរូបភាពសំបុត្របញ្ជាក់កំណើតនោះព្រោះវាជាការ *"បំពុលបរិយាកាស*[7]"។ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ និស្សិតម្នាក់ឈ្មោះ តៅ សារឿន ត្រូវបានចាប់ខ្លួន បន្ទាប់ពីបានឆ្លើយបញ្ចេញមតិយោបល់ថានឹងដាក់គ្រាប់បែកក្នុងពិធីប្រគល់សញ្ញាបត្រមួយដែលមានការអញ្ជើញចូលរួមថ្លែងសុន្ទរកថាដោយ

---

[4] ដោយ ឃី សុវុឌ្ឍី និង ANTHONY JENSEN "សុខ ទូច គំរាមប្តឹងអតីតនិស្សិតសាកលវិទ្យាល័យខេមរៈរបស់ខ្លួន" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦)។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1QjzKrm

[5] ដោយ គុច ណារ៉េន "លោក ហ៊ុន ម៉ាណែត ប្តឹងម្ចាស់ហ្វេសប៊ុកទាក់ទងការចោទថាកាប់ឈើ" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី១ ខែមករា ឆ្នាំ២០១៦)។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1T4OJf0

[6] ប៊ិច សុធារី "សកម្មជនគណបក្សសង្គ្រោះជាតិពីររូបជាប់ពន្ធនាគារដោយសារក្លែងសំបុត្រកំណើត" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥)។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1UUyezW

[7] ដោយ ឃួន ណារិម "សំបុត្របញ្ជាក់កំណើតក្លែងក្លាយធ្វើឲ្យនគរបាលបើកការស៊ើបអង្កេត" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥)។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1PGwjPo

ឧបនាយករដ្ឋមន្ត្រី ស ខេង ដោយសារនិស្សិតរូបនោះខឹងសម្បានឹងការរៀបចំកម្មវិធី[8]។ លោកត្រូវបានកាត់ទោសនិងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១៥ ខែ ប៉ុន្តែលោកបានអនុវត្តទោសតែរយៈពេលមួយខែប៉ុណ្ណោះ បន្ទាប់ពីបានសុំទោសលោកឧបនាយករដ្ឋមន្ត្រី ដោយបំភ្លឺថាពុំមានចេតនាប្រព្រឹត្តបទល្មើសដាក់ស្តែងណាមួយនោះទេ[9]។

សមាជិកព្រឹទ្ធសភាគណបក្ស សម រង្ស៊ី លោក ហុង សុខហួរ ត្រូវបានចាប់ខ្លួនដោយកម្លាំងនគរបាលកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ហើយ នៅថ្ងៃបន្ទាប់ត្រូវបានចោទប្រកាន់ពីបទក្លែងឯកសារសាធារណៈ និងញុះញង់ធ្វើឱ្យមានភាពចលាចលធ្ងន់ធ្ងរដល់សន្តិសុខជាតិ បន្ទាប់ពីលោកបានបង្ហោះវីដេអូឃ្លីបមួយនៅលើទំព័រហ្វេសប៊ុកដែលមានបញ្ចូលឯកសារសន្ធិសញ្ញាក្លែងក្លាយពីព្រំដែនកម្ពុជា-វៀតណាមឆ្នាំ១៩៧៩ ។ ការចាប់ខ្លួនលើរូបលោកបានកើតឡើងភ្លាមៗបន្ទាប់ពីសុន្ទរកថារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ចោទប្រកាន់លោកពីបទក្បត់ជាតិ ដែលការអំពាវនាវឱ្យមានការចោទប្រកាន់នេះធ្វើឡើងដោយហេតុផលនយោបាយ។ ពាក់ព័ន្ធនឹងករណីនេះដែរ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ លោក សម រង្ស៊ី ប្រធាន គ.ស.ជ ត្រូវបានកោះហៅមកសាកសួរពាក់ព័ន្ធនឹងបទសមគំនិតក្លែងឯកសារ និងញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ដោយសារសមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ បានបង្ហោះវីដេអូឃ្លីបនៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់លោក សម រង្ស៊ី។ ការឃាយឃីតាមផ្លូវតុលាការមកលើលោក សម រង្ស៊ី និង លោក ហុង សុខហួរ នេះ ត្រូវបានគេដឹងថាកើតឡើងក្នុងបរិបទនៃការបង្ក្រាបទៅលើបក្សជំទាស់ តែយ៉ាងណាក៏ដោយ ករណីទាំងនោះបង្ហាញថាហ្វេសប៊ុកបានក្លាយជាវេទិកាកណ្តាលសម្រាប់ទាមទារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋកម្ពុជា។ ពាក់ព័ន្ធនឹងករណីនេះដែរ យ៉ាងហោចណាស់អ្នកគ្រប់គ្រងទំព័រហ្វេសប៊ុកផ្លូវការរបស់លោក សម រង្ស៊ី ចំនួន ២ រូប ត្រូវបានចោទប្រកាន់ដែលបង្ខំឱ្យពួកគេភៀសខ្លួនទៅក្រៅប្រទេស[10]។

## ការគំរាមកំហែង ការព្រមាន និង ការដាក់ពិរុទ្ធខ្លួនឯង

ព្រឹត្តិការណ៍ទាំងនេះបានកើតឡើងផ្ទុយគ្នាពីបរិយាកាសដ៏អាប់អួចំពោះសេរីភាពខាងការបញ្ចេញមតិ ដោយសារថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគំរាមម្តងហើយម្តងទៀតលើអ្នកដែលរិះគន់ចំពោះអាជ្ញាធររបស់លោក។ ជាក់ស្តែង កាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ លោកបានព្រមានថា " *រាល់ទង្វើទាំងឡាយណាដែលបំផ្លាញដល់កិត្តិយសខ្ញុំនិងក្រុមគ្រួសារ ក្នុងនាមជានាយករដ្ឋមន្ត្រីនៃប្រទេសមួយគឺត្រូវតែទទួលខុសត្រូវ*

---

[8] ដោយ ម៉ិច ដារ៉ា "និស្សិតម្នាក់ត្រូវបានផ្តន្ទាទោសពីបទគំរាមដាក់គ្រាប់បែក តែទោសកាត់បន្ថយ" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥)។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/20NxJv5

[9] កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ មន្ត្រីក្រសួងមហាផ្ទៃម្នាក់ ឈ្មោះ ផេង វណ្ណៈ បានប្រឈមនឹងវិន័យរបស់គណៈកម្មការ វិន័យនគរបាលពាក់ព័ន្ធនឹងការបង្ហោះសារ និងរូបភាពកាំភ្លើងខ្លី និងគ្រាប់កាំភ្លើងចំនួនប្រាំពីរគ្រាប់នៅលើបណ្តាញហ្វេសប៊ុក គំរាមសម្លាប់លោក កឹម សុខា អនុប្រធាន គ ជ.ស.។ បន្ទាប់ពីការចោទប្រកាន់នោះ លោកត្រូវបានបញ្ឈរជើងការងារជាបណ្តោះអាសន្នរង់ចាំការស៊ើបអង្កេត។ ម.ស.ម.ក បែងចែកដាច់ពីគ្នារវាងករណីនេះ និងករណី លោក តៅ សារឿន ដោយសារករណី ផេង វណ្ណៈ ទទួលការអនុគ្រោះផ្នែកច្បាប់ជុំវិញការគំរាមសម្លាប់ ចំណែកឯករណី តៅ សារឿន ទទួលទោសពិន័យដោយពុំសមាមាត្រ។

[10] ដោយ ម៉ិច ដារ៉ា "តុលាការចេញដីកាចាប់ខ្លួនអ្នកគ្រប់គ្រងទំព័រហ្វេសប៊ុកដ៏មានប្រជាប្រិយរបស់លោក សម រង្ស៊ី"សារព័ត៌មាន*ខេមបូឌា ដេលី* (ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៥)។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1Q1HnbD

*ចំពោះមុខច្បាប់*" និងបានគំរាមទៀតថា " *ប្រសិនបើពូចង់ចាត់ការក្មួយ ៧ ម៉ោងយ៉ាងយូរ*"[11]។ កាលពីខែតុលា ឆ្នាំ២០១៥ នាយករដ្ឋមន្ត្រីថែមទាំងបានព្រមានអ្នកនយោបាយគណបក្សជំទាស់ឱ្យប្រកាន់អត្តចរិត"សុភាពរាបសាជាងនេះ" ចំពោះមតិយោបល់នៅលើបណ្តាញសង្គម ហើយលោកក៏បានរិះគន់ដោយផ្ទាល់ចំពោះតំណាងរាស្ត្រគណបក្សជំទាស់លោក យ៉ែម បុញ្ញឫទ្ធិ ដែលបានបញ្ចេញយោបល់លើបណ្តាញហ្វេសប៊ុកថា អ្នកនយោបាយគួរតែបើកចិត្តឱ្យទូលាយទទួលយកការរិះគន់ក្នុងន័យស្ថាបនា។ ឆ្លើយតបទៅនឹងការបង្ក្រាបលើការបញ្ចេញមតិយោបល់លើបណ្តាញអ៊ីនធឺណិត ថ្នាក់ដឹកនាំរបស់ គ.ស.ជ បានណែនាំសមាជិករបស់ខ្លួនឱ្យមានការប្រុងប្រយ័ត្ននៅពេលបញ្ចេញមតិលើបណ្តាញអ៊ីនធឺណិត ។ កាលពីថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០១៥ លោក កឹម សុខា ប្រធានស្តីទី គ.ស.ជ បានណែនាំដល់ប្រធានក្រុមយុវជន គ.ស.ជ ទាំងអស់ឱ្យរក្សានូវអត្តចរិតសុភាពរាបសាក្នុងការបញ្ចេញយោបល់ទាក់ទងនឹងរឿងនយោបាយ ជៀសវាងការបង្កបញ្ហាជាមួយគណបក្សប្រជាជនកម្ពុជា។ ការព្រមានគំរាមនិងការណែនាំទាំងនេះ អាចធ្វើឱ្យប៉ះពាល់ដល់ការពិភាក្សាដោយសេរីលើបញ្ហានយោបាយដែលពលរដ្ឋកម្ពុជាស្ទាក់ស្ទើរក្នុងការជជែកអំពីបញ្ហានេះ និងរារាំងដល់ការចូលរួមសកម្មក្នុងកិច្ចសន្ទនានយោបាយ។ អ្នកនយោបាយជាន់ខ្ពស់នៅកម្ពុជាបានទទួលស្គាល់អំពីគុណតម្លៃនៃបណ្តាញសង្គមដែលនាំពួកគេឱ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋសាមញ្ញ ប៉ុន្តែពួកគេមិនត្រូវរារាំងការប្រើប្រាស់បណ្តាញសង្គមក្នុងការលើកកម្ពស់ការចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យក្នុងការបញ្ចេញទស្សនៈនិងមតិយោបល់ផ្សេងៗឡើយ។

## ការលាក់បាំងនូវសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យា

ផ្ទុយពីការបង្ក្រាបដ៏ធ្ងន់ធ្ងរទៅលើសេរីភាពខាងការបញ្ចេញមតិនៅលើបណ្តាញសង្គមនៅក្នុងខែឧសភា ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជា "រដ្ឋាភិបាល" បានប្រកាសឡើងពីគោលបំណងរបស់ខ្លួនក្នុងការបង្កើត "ច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យា" ជាលើកដំបូងនៅកម្ពុជាដើម្បីគ្រប់គ្រងមាតិកានៅលើបណ្តាញអ៊ីនធឺណិតនិងរារាំង "*ក្រុមមនុស្សអាក្រក់*" ក្នុងការចែកចាយព័ត៌មានមិនពិត[12]។ បើទោះបីជាមានការស្នើសុំពីក្រុមអង្គការសង្គមស៊ីវិលមួយចំនួនក្តី រដ្ឋាភិបាលបានបដិសេធចេញផ្សាយសេចក្តីព្រាងច្បាប់ផ្លូវការ បើទោះជាសេចក្តីព្រាងនោះបានបែកធ្លាយកាលពីឆ្នាំ២០១៤ ហើយក៏ដោយ។ កង្វះតម្លាភាពក្នុងការធ្វើសេចក្តីស្នើច្បាប់នេះរារាំងបន្ថែមទៀតដល់ការចូលរួមដោយបើកចំហនិងដំណើរការលទ្ធិប្រជាធិបតេយ្យ។ មានប្រសាសន៍នៅក្នុងកិច្ចប្រជុំពិនិត្យមើលលើសេចក្តីស្នើច្បាប់កាលពីខែឧសភា ឆ្នាំ២០១៥ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានថ្លែងថា ចាំបាច់ត្រូវមានច្បាប់គ្រប់គ្រងដើម្បីដាក់ពិរុទ្ធទៅលើ "*ក្រុមមនុស្សអាក្រក់*" ដែល "*រិះគន់រដ្ឋាភិបាល* " និងទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិតនៅលើបណ្តាញអ៊ីនធឺណិត[13]។

---

[11] ដោយ គុច ណារ៉េន "លោក ហ៊ុន ម៉ាណែត ប្តឹងម្ចាស់ហ្វេសប៊ុកទាក់ទងការចោទថាកាប់ឈើ" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី១ ខែមករា ឆ្នាំ២០១៦)។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1T4OJf0

[12] Bridget Di Certo និង គឹម យុទ្ធណា "កម្ពុជាធ្វើច្បាប់គ្រប់គ្រងអ៊ីនធឺណិតធ្វើឲ្យមានការបារម្ភការរឹតត្បិត" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២)។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1Jrl1GP

[13] ម៉ិច ដារ៉ា "ក្រសួងលើកឡើងថា ច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យាការពារកិត្តិយសរដ្ឋាភិបាល" សារព័ត៌មាន*ខេមបូឌា ដេលី* (ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥) ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1PYDxP7

សេចក្តីស្នើច្បាប់ដ៏ចម្រូងចម្រាសនេះ ប្រសិនបើត្រូវបានអនុម័តក្នុងទម្រង់បែកធ្លាយដែល ម.ស.ម.ក ទទួលបានមែននោះនឹងរឹតត្បិតយ៉ាងធ្ងន់ធ្ងរដល់សេរីភាពខាងការបញ្ចេញមតិ និងផ្តល់អំណាចបន្ថែមទៀតដល់អាជ្ញាធរដើម្បីចាប់ខ្លួនអ្នកដែលបញ្ចេញមតិយោបល់រិះគន់រដ្ឋាភិបាលនៅលើបណ្តាញអ៊ីនធើណិត។

## សេរីភាពខាងការបញ្ចេញមតិ

នៅកម្ពុជាសេរីភាពខាងការបញ្ចេញមតិត្រូវបានការពារក្រោមច្បាប់ជាតិ និងអន្តរជាតិ។ មាត្រា៤១នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា "រដ្ឋធម្មនុញ្ញ" ផ្តល់នូវ "*សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សារព័ត៌មាន ការបោះពុម្ពផ្សាយ និងជួបប្រជុំ* " សិទ្ធិទាំងនោះមិនអាច "*ប្រើប្រាស់ដើម្បីរំលោភបំពានដល់សិទ្ធិអ្នកដទៃ ប៉ះពាល់ដល់ទំនៀមទំលាប់ល្អរបស់សង្គម រំលោភច្បាប់និងបទបញ្ជាសាធារណៈនិងសន្តិសុខជាតិ*"ឡើយ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស"ស.ប.ស.ស" និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ "ក.អ.ស.ព.ន" មានអានុភាពនៅក្នុងច្បាប់កម្ពុជាដូចដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០៧[14]។ មាត្រា១៩នៃលិខិតូបករណ៍អន្តរជាតិទាំងពីរនេះការពារសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

## ការអនុញ្ញាតឱ្យមានការកម្រិតលើសេរីភាពខាងការបញ្ចេញមតិ

យោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ មានហេតុផលស្របច្បាប់មួយចំនួនដែលអាចរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ ដូចជាការរក្សានូវសណ្តាប់ធ្នាប់សាធារណៈ និងការការពារលើសិទ្ធិឯកជនភាពរបស់អ្នកដទៃ។ ករណីនេះត្រូវមានតុល្យភាពរវាងសិទ្ធិផ្សេងៗដែលពាក់ព័ន្ធ ប៉ុន្តែសេរីភាពខាងការបញ្ចេញមតិគួរត្រូវបានការពារជាពិសេសក្នុងបរិបទនយោបាយ។ ការរិះគន់ទៅលើមន្ត្រីសាធារណៈគឺមានសារៈសំខាន់ក្នុងការធ្វើឱ្យបុគ្គលដែលអនុវត្តមុខងារសាធារណៈទាំងនោះមានទំនួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។ ដូច្នេះហើយការការពារផ្លូវច្បាប់ទៅលើកិត្តិយស និងឯកជនភាពរបស់រូបវន្តបុគ្គលគឺទន់ខ្សោយជាងការគោរពបុគ្គលសាធារណៈ។ សារៈសំខាន់ពិតប្រាដកនៃសេរីភាពខាងការបញ្ចេញមតិនៅក្នុងវិស័យនយោបាយមានបញ្ជាក់យ៉ាងច្បាស់ក្នុងបទដ្ឋានច្បាប់អន្តរជាតិ។

គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិបានលើកឡើងអំពីសារៈសំខាន់នៃការទទួលយកការរិះគន់បុគ្គលសាធារណៈនៅក្នុងសង្គមប្រជាធិបតេយ្យសេរី ដូចខាងក្រោម ៖

> "*នៅក្នុងកាលៈទេសៈនៃការជជែកដេញដោលពាក់ព័ន្ធនឹងបុគ្គលសាធារណៈ ហើយ និងស្ថាប័នសាធារណៈនៅក្នុងវិស័យនយោបាយ កតិកាសញ្ញានេះបានឱ្យតម្លៃខ្ពស់ទៅលើការបញ្ចេញមតិយោបល់ ដូច្នេះ អង្គហេតុដ៏តូចមួយដែលចាត់ទុកសេរីភាពខាងការបញ្ចេញមតិជាការប្រមាថដល់បុគ្គលសាធារណៈនោះ មិនអាចបំពេញនូវលក្ខណ្ឌគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសព្រហ្មទណ្ឌបានទេ ទោះបីជាបុគ្គលសាធារណៈអាចទទួលអត្ថប្រយោជន៍ពីកតិកាសញ្ញានេះក៏ដោយ។ ជាងនេះទៅទៀត បុគ្គលសាធារណៈរួមទាំងអ្នកដែលមានសិទ្ធិអំណាចខ្ពស់ក្នុងវិស័យ*

[14] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

*នយោបាយដូចជា ប្រមុខរដ្ឋ និងរដ្ឋាភិបាលគឺជាអ្នកដែលនឹងត្រូវទទួលរងការរិះគន់និងជំទាស់ក្នុងវិស័យនយោបាយ"[15]។*

ម្យ៉ាងទៀត ទំហំនៃការប្រើប្រាស់បទបរិហារកេរ្តិ៍ដើម្បីគាបសង្កត់ការរិះគន់លើបុគ្គលសាធារណៈ និងអ្នកនយោបាយដូចដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក៏ត្រូវបានថ្កោលទោសដោយគណៈកម្មាធិការនេះផងដែរ ៖

*"ច្បាប់បរិហារកេរ្តិ៍ត្រូវតែតាក់តែងឡើងដោយមានការយកចិត្តទុកដាក់ដើម្បីធានាថាច្បាប់ទាំងនោះ... មិនត្រូវបានយកមកអនុវត្តដើម្បីរារាំងសេរីភាពខាងការបញ្ចេញមតិ។ ច្បាប់ទាំងនោះ ជាពិសេសច្បាប់បរិហារកេរ្តិ៍ក្នុងរឿងព្រហ្មទណ្ឌគួរតែដាក់បញ្ចូលនូវខចែងដែលគាំទ្រដល់ការពិត ហើយមិនគួរយកមកអនុវត្តក្នុងទម្រង់នៃការបញ្ចេញមតិយោបល់ដែលមិនមែនជាលក្ខណ្ឌដើម្បីដាក់ទោសទណ្ឌឡើយ។ យ៉ាងហោចណាស់មតិយោបល់លើកឡើងអំពីបុគ្គលសាធារណៈ ត្រូវរួចផុតពីការដាក់ទោសព្រហ្មទណ្ឌ ឬក៏ឱ្យធ្វើការបកស្រាយ កែតម្រូវនូវពាក្យសម្តីមិនពិតដែលបានចេញផ្សាយទៅហើយនោះ ដោយពុំមានការព្យាបាទ។"*

ការកើនឡើងនូវការចាប់ខ្លួនប្រជាពលរដ្ឋដោយសារការរិះគន់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងបុគ្គលសាធារណៈល្បីៗមួយចំនួន បានគំរាមកំហែងដល់ដំណើរការលទ្ធិប្រជាធិបតេយ្យក្នុងបរិយាកាសសេរីនិងបើកចំហនៅកម្ពុជា។ ការប្រើប្រាស់បទបរិហារកេរ្តិ៍ និងការញុះញង់ដើម្បីរារាំងដល់ការរិះគន់ទៅលើបុគ្គលសាធារណៈគឺជាការរំលោភបំពានដល់សិទ្ធិសេរីភាពមូលដ្ឋានខាងការបញ្ចេញមតិ ដូចដែលបានប្រកាសនៅក្នុងលិខិតូបករណ៍អន្តរជាតិនិងស្ថាប័នអន្តរជាតិជាច្រើន។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកស្រី ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ + ៨៥៥ (០) ១៧ ៥២៨ ០២១ ឬ អ៊ីម៉ែល ៖ chhunly.chhay@cchrcambodia.orgឬ លោក ផាត ដឺប្រូន ទីប្រឹក្សា ម.ស.ម.ក តាមរយៈទូរសព្ទ ៖ + ៨៥៥ (០) ៨៩ ៥៣៦ ២១៥ ឬ អ៊ីម៉ែល៖ pat.debrun@cchrcambodia.org។**

[15] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីអត្ថាធិប្បាយទូទៅលេខ៣៤ មាត្រា១៩ ៖ សេរីភាពខាងការបញ្ចេញគំនិតនិងមតិ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១។ ព័ត៌មានពិស្តារ សូមចុចនៅលើតំណភ្ជាប់ ៖ http://bit.ly/1xmySgV